# មេរៀនទី៣៣៖ ផារ៉ោនឱ្យយ៉ូសែបធ្វើជាអ្នកគ្រប់គ្រង

## លោកុប្បត្តិ ៣៩៖ ២០-៤១៖ ៤៩

**មេរៀនសម្រាប់គ្រូ** *( យូធូបលីង )*៖ **https://youtu.be/NY_BhkbOunk**

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/CXo0XiRdrYw

**គោលបំណង៖ ព្រះអង្គចង់ឱ្យយើងបំរើទ្រង់**

**ខគម្ពីរចងចាំ៖** កូល៉ុស ៣៖២៣ *"ហើយការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ"។*

**ចំរៀង** *( យូធូបលីង )*៖

១. គឺជាការល្អដែលសរសើរព្រះ https://youtu.be/Z91SULEHfho
២. ចូរសសើរព្រះយេស៊ូវ https://youtu.be/PtAbR7-xroM
៣. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

### ១. អធិស្ឋាន

អរគុណព្រះអង្គសំរាប់ព្រះពរថ្មីម្តងទៀត បានប្រទានពរឱ្យកូនៗបានជួបគ្នានៅក្នុងថ្ងៃនេះ ។ កូនសូមទូលថ្វាយ ការអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន!

### ២. ចំរៀង

*សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

### ៣. ល្បែងកំសាន្ត "ត្រូវបំរើព្រះដោយចេញពីចិត្តរបស់យើង"



សម្ភារៈដែលត្រូវការ៖ បោះពុម្ពរូបបេះដូង រួចកាត់ពាក់កណ្ដាល (សូមមើលរូបខាងក្រោមដើម្បីបោះពុម្ព)

១. នៅពេលដែលយើងបំរើព្រះ ព្រះអង្គចង់ឱ្យយើងបំរើទ្រង់ដោយអស់ពីចិត្ត។

២. នៅក្នុងក្រដាសដែលមាន រូប បេះដូងនៅខាងក្រោម សូមកាត់រូបបេះដូងនីមួយៗជាពីរចំណែកស្មើគ្នា។

៣. ពេលភ្លេងចាប់ផ្តើមលេងសូម ចែកបំណែកបេះដូងទៅកូនសិស្សម្នាក់មួយបំណែកឲ្យបានគ្រប់ៗគ្នា រួចឲ្យពួកគេដើរស្វែងរកបេះដូងមួយចំណែកទៀត ដែលជាគូរជាមួយបេះដូងដែលគេមាន។

៤. អ្នកណាដែលរកឃើញដៃគូហើយពួកគេអាច អង្គុយ ចុះបាន។
៥.តើព្រះចង់ឱ្យយើងជាបេះដូងមួយចំហៀង *(លើករូបបេះដូង១ចំហៀងនោះឡើងលើ)* ឬជាបេះដូងមួយដែលពេញលេញ?(*លើកបេះដូង១ចំហៀងទៀតមកផ្គុំគ្នា*)។
៦.ព្រះសប្បាយព្រះទ័យនៅពេលដែលយើងបំរើទ្រង់ ហើយព្រះអង្គកាន់តែសព្វព្រះហឫទ័យនៅពេលដែលយើងបំរើទ្រង់ឱ្យអស់ពីចិត្ត។
៧.ឥឡូវនេះយើងនិង ទៅមើលពីបុរសម្នាក់នៅក្នុងព្រះគម្ពី ដែលគាត់បានបំរើព្រះអង្គដោយអស់ពីចិត្តរបស់គាត់។

## ៤. ការណែនាំពីមេរៀន

សាច់រឿងនៅក្នុងព្រះគម្ពីរនៅថ្ងៃនេះគឺប្រាប់យើងពីយ៉ូសែបបានបំរើ និងថ្វាយបង្គំព្រះនៅគ្រប់ទីកន្លែង ដែលគាត់ទៅ។ យ៉ូសែបបំរើព្រះដោយអស់ពីចិត្ត ពីព្រោះគាត់ដឹងថា ព្រះឱ្យតំលៃចំពោះការបំរើរបស់គាត់។ ដោយសារតែការស្អប់ បងៗរបស់គាត់បានលក់យ៉ូសែបឱ្យ ធ្វើជាទាសករនៅប្រទេសអេស៊ីប។ នៅពេលមួយ ដែលយ៉ូសែបបានក្លាយជាទាសកររបស់ មេទ័ពធំម្នាក់នៅអេហ្ស៊ីប។ យ៉ូសែបប្រឹងប្រែងធ្វើការដោយស្មោះត្រង់ និងអស់ចិត្តរបស់គាត់។ គាត់ត្រូវបានចៅហ្វាយ ឱ្យតម្លៃ និងទុកចិត្តដោយឱ្យគាត់ត្រួតត្រាលើផ្ទះ និងទ្រព្យសម្បត្តិទាំងអស់ដែលចៅហ្វាយមាន។ បន្ទាប់មកមានមនុស្សនិយាយបង្ខូចយ៉ូសែប ហើយគាត់ត្រូវបានគេយកទៅដាក់គុកទាំងដែលគាត់គ្មានកំហុសអ្វីសោះ។ តើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះយ៉ូសែប?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងគុកយ៉ូសែបតែងចាំថាព្រះទ្រង់គង់ជាមួយគាត់គ្រប់ពេល។ យ៉ូសែបទុកចិត្តព្រះហើយអ្វីដែលគាត់ធ្វើគឺត្រឹមត្រូវ ទោះបីជាអ្នកដទៃប្រព្រឹត្តិបែបណាដាក់គាត់ក៏ដោយ។ យ៉ូសែបក៏បានជួយដល់អ្នកទោសផ្សេងទៀត យ៉ូសែបដឹងថាព្រះសក្តិសមនឹងទទួលការបម្រើដោយអស់ពីចិត្តរបស់គាត់ មិនថាមានអ្វីកើតឡើងនោះទេ គាត់បានជ្រើសរើសធ្វើនូវអ្វីដែលត្រឹមត្រូវ។ ថ្ងៃមួយយ៉ូសែបត្រូវបានគេហៅទៅដើម្បីជួយកាត់បិន្តរបស់ស្តេចផារ៉ោន។ ដោយសារមានជំនួយពីព្រះ យ៉ូសែបអាចកាត់សុបិន្តរបស់ផារ៉ោនបានសុបិន្តនោះបង្ហាញថានឹងមានភាពសំបូរសប្បាយ៧ឆ្នាំ និង៧ឆ្នាំទៀតមានគ្រោះទុរ្ភិក្ស។ យ៉ូសែបបំរើព្រះដោយក្តីជំនឿហើយអ្នកផ្សេងក៏មើលឃើញវត្តមានរបស់ព្រះគង់នៅជាមួយគាត់ដែរ។ ផារ៉ោនពេញចិត្តជាមួយនិងយ៉ូសែបណាស់ហើយគាត់ក៏បានអញ្ជើញយ៉ូសែបមករស់នៅក្នុងរាជវាំង។ ទោះជាយ៉ូសែបគ្មានសេរីភាពតែគាត់ក៏មិនបានជាប់នៅក្នុងគុកទៀតដែរ។ មិនយូរប៉ុន្មានផារ៉ោនបានលើកយ៉ូសែបឱ្យធ្វើជាមេបញ្ជាការទី២ របស់គាត់មានន័យថាយ៉ូសែបមានការ ទទួលខុសត្រូវច្រើនជាងអ្នកផ្សេងទៀតនៅអេហ្ស៊ីប គឺយ៉ូសែបនៅក្រោមតែផារ៉ោនម្នាក់ប៉ុណ្ណោះ។ អ្វីដែលជាការអស្ចារ្យរបស់យ៉ូសែបនោះគឺគាត់បំរើព្រះគ្រប់កាលៈទេសៈទោះជាអ្នកដទៃធ្វើអាក្រក់ឬធ្វើល្អ ដាក់គាត់ក៏ដោយ យ៉ូសែបបានធ្វើអ្វីដែលមាននៅក្នុងខគម្ពីរចងចាំរបស់យើងថ្ងៃនេះមិនថាគាត់ បានធ្វើទេ គឺគាត់ធ្វើសំរាប់ព្រះអស់ពីបេះដូងរបស់គាត់។ យ៉ូសែបមិនបានព្យាយាមយកចិត្តអ្នកជាប់គុក ឬចៅហ្វាយ ឬក៏ស្តេចទេ តែគាត់បានបំរើព្រះដោយចេញពីចិត្តរបស់គាត់។ ហើយព្រះ

ទ្រង់ស្រលាញ់ការ បំរើរបស់យ៉ូសែប ហើយព្រះអង្គបានប្រទានពរដល់យូសែបតាមអ្វីដែលគាត់បានធ្វើ។ យើងត្រូវតែបំរើ ព្រះអង្គដោយចេញពីចិត្តដូចយ៉ូសែបអញ្ចឹងដែរ!

## ៦. សំនួរពិភាក្សា

១. ហេតុអីបានជាយ៉ូសែបជាប់គុក? (*មានអ្នកនិយាយបង្ខូចគាត់*)

២. តើនៅក្នុងគុកយ៉ូសែបបំរើព្រះដោយរបៀបណា? (*ដោយចិត្ត ឬ បេះដូងរបស់គាត់*)

៣. តើយ៉ូសែបជួយផារោនយ៉ាងដូចម្តេច? (*យ៉ូសែបកាត់ស្រាយសុបិន្តរបស់ផារ៉ោន*)

៤. តើផារ៉ោនបានយល់សប្តិឃើញអ្វី? (*គាត់ឃើញគោសុ្តម៧ លេបគោធាត់៧ ហើយគួរស្រូវ៧ធំ ថ្លោសៗត្រូវស្រូវតូចៗស្កក ៧លេប* )

៥. តើអ្នកគិតថាអ្នកអាចបំរើព្រះដោយចេញពីចិត្តរបស់អ្នកដែរឬទេ បើទោះជាពេលខ្លះមានការអាក្រក់កើតឡើងចំពោះអ្នកក៏ដោយ? (*ចា៎ស/បាទ យើងគួរតែទុកចិត្តព្រះគ្រប់ពេល*)

## ៧. ខគម្ពីរចងចាំ

**កូល៉ុស ៣:២៣** *"ហើយការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយ ដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ"*។

**ខគម្ពីរចងចាំបែបឆ្នៃប្រឌិត:** ដើម្បីជួយឱ្យកុមារឆាប់ចងចាំ ( ដោយ ប្រើបាតដៃ) របៀធ្វើ៖ ឱ្យកុមារគូរបាតដៃនៅលើក្រដាស បន្ទាប់មកកាត់រូបបាតដៃនោះ ហើយសរសេរខគម្ពីរឱ្យអស់ពាក្យដាក់នៅលើម្រាមដៃនីមួយៗ។ សូមមើលលើរូបភាពបាតដៃដែលបានសរសេរខគម្ពីរជា ឧទាហរណ៍នៅឆ្វេងនេះ។




## ៨. ហត្ថកម្ម



ព្រីនរង្វង់ខ្សែបូហើយឱ្យកុមារកាត់វាចេញមកហើយផាត់ពណ៌ដោយខ្លួនឯង។ ឱ្យសិស្សសរសេរឈ្មោះពួកគេ នៅក្នុងរង្វង់ ហើយសរសេរ "បំរើព្រះ" នៅលើខ្សែបូមួយ និង "អស់ពីចិត្តខ្ញុំ" នៅលើខ្សែបូមួយទៀត។

## ៩. ចំរៀង (*សូមជ្រើសរើសចម្រៀងមួយបទខាងលើហើយច្រៀងជាមួយសិស្ស*)

## ១០. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ( សូមអាន ហើយអធិស្ឋានមុនពេលបង្រៀន )**
ដូចដែលយើងស្រលាញ់ និងបំរើព្រះ យើងបានលូតលាស់ដោយរឹងមាំ ហើយកាន់តែដូចជា ព្រះ គ្រីស្ទ។ ព្រះប្រើការលូតលាស់របស់គ្រីស្ទបរិសទ័ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់មនុស្សគ្រប់ទីកន្លែង។ យ៉ូសែបបាននាំការផ្លាស់ប្តូរនៅកណ្តាលកាលៈទេសៈចំលែក និងកាលៈ ទេសៈលំបាក របស់គាត់។ តើអ្នកយល់ថាអ្នកបាននាំការផ្លាស់ប្តូរសំរាប់ជីវិតសិស្សៗរបស់អ្នកដែរឬទេ? សូមស្ងៀមស្ងាត់ ហើយ អធិស្ឋានជាមួយពាក្យទាំងនេះ "ព្រះយេស៊ូវសូមជួយកូន ឱ្យយល់ ពីសារៈសំខាន់នៃការដឹកនាំសិស្សទាំងអស់។ អរគុណដែលបានប្រើកូន-ដើម្បីជួយឱ្យ ពួកគេកាន់ តែលូតលាស់ហើយខិតជិតក្បែរទ្រង់! អាម៉ែន" ។









